# មេរៀនទី៦២៖ ព្រះយេស៊ូវប្រោសជម្ងឺម្ដាយក្មេកពេត្រុស

## ម៉ាកុស ១៖២៩-៣៩

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/8d1C0-LU8PA

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/vKE3zLwUai4

**គោលបំណង៖** ព្រះយេស៊ូវយកចិត្តទុកដាក់ជាមួយយើង។

**ខគម្ពីរចងចាំ៖ លូកា ៦៖១៩** *"ទាំងអស់រកពាល់ទ្រង់ ដ្បិតមានព្រះចេស្ដាចេញពីទ្រង់ មកប្រោសឲ្យជាទាំងអស់គ្នា"*។

**ចំរៀង** ( *យូធូបលីង* )៖

១.ព្រះអង្គទ្រង់ព្រះអស្ចារ្យ https://youtu.be/QXEVqO94wpg

២.ព្រះយើងជាព្រះអស្ចារ្យ https://youtu.be/TU6HfxJXLvQ

៣.នៅកន្លែងនេះមានក្តីស្រលាញ់ https://youtu.be/iUGQmu1AmLI

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «ឆក់»

សម្ភារៈដែលត្រូវការ៖ ដបទឹក សរសេរ "X" និង "0" នៅលើដុំថ្មមួយ



១. ចែកកុមារជា២ក្រុមឲ្យស្មើគ្នា

២. ឲ្យកុមារអង្គុយចុះជាជួរទាំង២ក្រុម ទល់មុខគ្នា ហើយឲ្យមេក្រុមអង្គុយនៅខាងដើមគេជិតគ្រូ

៣.កុមារដែលអង្គុយនៅចុងគេបង្អស់គឺជាកុមារដែលឈឺ ហើយត្រូវការការប្រោសឲ្យជា។ ដើម្បីជួយកុមារ ដែលឈឺនោះឲ្យជាបានគឺកុមារនៅក្នុងក្រុមទាំងមូលត្រូវធ្វើតាមការណែនាំរបស់គ្រូ។

៤. គ្រូបោះដុំថ្មនៅជិតមេក្រុមទាំងពីរ។ ប្រសិនបើដុំថ្មធ្លាក់ត្រូវអក្សរ "X" មេក្រុមមិនត្រូវធ្វើអ្វីទាំងអស់។

៥. ប៉ុន្តែប្រសិនបើដុំថ្មធ្លាក់ត្រូវអក្សរ "0" មេក្រុមត្រូវឆក់ដៃអ្នកដែលនៅបន្ទាប់ពីគាត់ ហើយសមាជិកក្រុម ទាំងអស់ត្រូវឆក់ដៃគ្នាបន្តបន្ទាប់រហូតដល់អ្នកដែលឈឺនោះ ហើយកុមារដែលឈឺនោះត្រូវចាប់ដបទឹក ដែលនៅជិតគាត់ ហើយក្រុមនោះនឹងឈ្នះល្បែងនេះ។

៦. សូមពន្យល់កុមារថា យើងត្រូវតែឆក់គ្នាឲ្យជាប់ ដើម្បីឲ្យយើងអាចជួយឲ្យនរណាម្នាក់ជាបាន ក៏ដូចគ្នានេះ ដែលយើងត្រូវតែនៅជាប់ជាមួយព្រះ ដើម្បីឲ្យយើងអាចទទួលបានការប្រោសឲ្យជាយ៉ាងពិតប្រាកដ។

### ៤. ការណែនាំមេរៀន

សូមឲ្យកុមារណាម្នាក់ចែកចាយទីបន្ទាល់ពីក្រុមគ្រួសារគាត់ដែលមានជម្ងឺ។ សូមរំលឹកកុមារថា នៅពេល

គេអធិស្ឋានទៅកាន់ព្រះនោះព្រះអង្គនឹងប្រោសព្យាបាលឲ្យគេបានជា(ដូចជា ឈឺក្បាល ចុកពោះ ក្ដៅខ្លួន ក្អក ។ល។)
ថ្ងៃនេះយើងនឹងលឺពីសាច់រឿងនៅក្នុងព្រះគម្ពីរ ដែលមានស្ត្រីម្នាក់គាត់មានជំងឺ ហើយព្រះអង្គប្រោសព្យាបាលជំងឺគាត់ឲ្យជា។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅក្នុងបទគម្ពីរថ្ងៃនេះ (**ម៉ាកុស ១៖២៩-៣៩**) យើងនឹងបានដឹងថា ម្ដាយក្មេករបស់ស៊ីម៉ូនឈឺ។ ក្រោយមកព្រះយេស៊ូវបានប្ដូរឈ្មោះស៊ីម៉ូនទៅជាពេត្រុស ដូច្នេះអ្នកដែលឈឺគឺជាម្ដាយក្មេករបស់ ពេត្រុស។ យើងមិនដឹងថា ម្ដាយក្មេករបស់ស៊ីម៉ូនឈឺយូរប៉ុណ្ណាហើយនោះទេ ប៉ុន្តែព្រះយេស៊ូវគ្រាន់តែចាប់ដៃគាត់ ហើយគាត់ ក៏បានធូរឡើងភ្លាម! គាត់បានជាសះស្បើយមួយរំពេច ហើយបន្ទាប់មកគាត់ក៏ចាប់ផ្ដើមបម្រើពួកគេ!

តើអ្នកគិតថាហេតុអ្វីបានជាព្រះយេស៊ូវប្រោសស្ត្រីម្នាក់នេះ? ព្រះយេស៊ូវបានប្រោសគាត់ដោយសារ ទ្រង់យកចិត្តទុកដាក់ចំពោះគាត់។ ព្រះយេស៊ូវមិនចង់ឱ្យយើងមានអារម្មណ៍ឈឺចាប់ ឬសោកសៅឡើយ។ ទ្រង់មិនមែនជួយស្ត្រីម្នាក់នេះដោយសារទ្រង់ស្គាល់ពេត្រុសប៉ុណ្ណោះទេ។ នៅថ្ងៃនេះ គេបាននាំអ្នកជំងឺផ្សេងទៀត មករកទ្រង់ ហើយទ្រង់ក៏បានប្រោសពួកគេឲ្យជាសះស្បើយដែរ។

ព្រះយេស៊ូវបានយកចិត្តទុកដាក់ចំពោះមនុស្សគ្រប់គ្នា។ ទ្រង់មានកម្លាំង និងអំណាចព្យាបាលពីព្រះ ហើយទ្រង់បានប្រើវាដើម្បីធ្វើការអស្ចារ្យ។ ទ្រង់បានព្យាបាលមនុស្សជាច្រើន។ ប៉ុន្តែអ្នកដឹងទេថា ជាអ្វី? ប្រហែលជាព្រះយេស៊ូវត្រូវខិតខំ និងប្រឹងប្រែងជាងនេះទៀត ដើម្បីធ្វើកិច្ចការទាំងអស់នោះ។ ពិតណាស់ ទ្រង់ជាបុត្រារបស់ព្រះ ប៉ុន្តែទ្រង់ក៏ជាមនុស្ស ហើយទ្រង់ក៏ចេះហត់នឿយដែរ។ ពេលខ្លះ ព្រះយេស៊ូវក៏ត្រូវការពេលវេលាផ្ទាល់ខ្លួនផងដែរ។

បទគម្ពីរថ្ងៃនេះប្រាប់យើងថា បន្ទាប់ពីទ្រង់បានព្យាបាលដល់មនុស្សជាច្រើន ព្រះយេស៊ូវបានចេញទៅកន្លែងមួយដែលទ្រង់អាចនៅតែអង្គទ្រង់បាន។ ប្រហែលជាទ្រង់ត្រូវការរំលឹក និងនឹកចាំពីព័ន្ធកិច្ច របស់ទ្រង់នៅលើផែនដីឡើងវិញ។ ហើយប្រហែលជាទ្រង់ក៏អរព្រះគុណព្រះជាម្ចាស់ចំពោះការអស្ចារ្យ ដែលកំពុងកើតឡើងដែរ។ ជាការពិតណាស់ ព្រះយេស៊ូវគឺជាព្រះ ដូច្នេះពេលខ្លះយើងមានការភ័ន្តច្រឡំ ក្នុងការគិត អំពីទ្រង់ពេលដែល ព្រះអង្គអធិស្ឋាន ប៉ុន្តែទ្រង់បានធ្វើការអធិស្ឋាន ដោយទ្រង់ចង់បង្ហាញពីសារៈសំខាន់នៃការអធិស្ឋាន។ យើងគួរអធិស្ឋានជានិច្ចដូចជាព្រះយេស៊ូវ។

ក្រោយពីអធិស្ឋានរួច ពួកសិស្សបានមករកទ្រង់។ ពួកគេបាននិយាយថាមនុស្សគ្រប់គ្នាកំពុងស្វែងរក ព្រះ-អង្គ។ ប៉ុន្តែព្រះយេស៊ូវបានពន្យល់ថា ពួកគេគួរទៅភូមិក្បែរនោះជំនួសវិញ ដើម្បីឲ្យទ្រង់អាចផ្សព្វផ្សាយនៅទីនោះបាន។

ព្រះយេស៊ូវត្រូវបានបញ្ជូនមកផែនដីដើម្បីធ្វើការប្រោសលោះ ផ្សព្វផ្សាយ បង្រៀន ស្រឡាញ់ យកចិត្តទុកដាក់ និងបង្ហាញពីទំហំនៃសេចក្តីស្រឡាញ់របស់ព្រះចំពោះប្រជារាស្ត្រទ្រង់។ អ្វីដែលសំខាន់ បំផុតនោះគឺទ្រង់បាន យាងមកសុគត ដើម្បីឲ្យយើងអាចមានជីវិតអស់កល្បជានិច្ចវិញ។ ទ្រង់បានយកចិត្តទុកដាក់ចំពោះការឈឺ ចាប់របស់យើងទាំងខាងក្នុង និងខាងក្រៅ។ ទ្រង់មានព្រះជន្មរស់ឡើងវិញ ដើម្បីឲ្យយើងមានជីវិតរស់ឡើងវិញដែរ។ ចូរមានសង្ឃឹម ហើយចងចាំពីការសន្យារបស់ទ្រង់ដែរថា ព្រះយេស៊ូវនឹងនៅ

ជាមួយយើងជានិច្ច។ ទ្រង់ព្យាបាល ការឈឺចាប់ខាងឯសាច់ឈាមរបស់យើង ប៉ុន្តែអ្វីដែលសំខាន់បំផុត នោះគឺ ទ្រង់ក៏បានព្យាបាលបញ្ហាផ្លូវចិត្តរបស់យើងដែរ។ ព្រះយេស៊ូវយកចិត្តទុកដាក់ចំពោះយើងជានិច្ច!

## ៦. សំនួរពិភាក្សា

១. តើនរណាមានជម្ងឺ? *( ម្តាយក្មេករបស់ស៊ីម៉ូន/ពេត្រុស )*

២. តើព្រះយេស៊ូវត្រូវចំណាយពេលប៉ុន្មានដើម្បីប្រោសគាត់ឲ្យជា? *(លឿនណាស់ ទ្រង់គ្រាន់តែចាប់ដៃគាត់ ហើយគាត់ក៏បានធូរស្បើយ)*

៣. តើមានអ្វីកើតឡើងបន្ទាប់ពីព្រះអង្គបានព្យាបាលម្តាយក្មេករបស់ពេត្រុស? *(នាងក៏បានបំរើព្រះយេស៊ូវភ្លាមៗ)*

៤. តើព្រះយេស៊ូវមានអំណាចជាងគ្រូពេទ្យយ៉ាងណា? *(ព្រះយេស៊ូវអាចព្យាបាលការឈឺចាប់របស់យើងទាំងខាងក្នុង និងខាងក្រៅ)*

## ៧. ល្បែងកំសាន្ត «ព្រះយេស៊ូវបញ្ជា»



១. ឲ្យកុមារឈរជាជួរ ហើយប្រុងប្រយ័ត្នក្នុងការស្តាប់គ្រូ

២. ប្រសិនបើគ្រូនិយាយថា “ព្រះយេស៊ូវបញ្ជាឲ្យ….” កុមារ ទាំងអស់ត្រូវតែធ្វើតាម។

៣. ប៉ុន្តែប្រសិនបើគ្រូមិនបាននិយាយពាក្យថា “ព្រះយេស៊ូវ បញ្ជា…” នោះកុមារមិនត្រូវធ្វើតាមគ្រូនោះទេ។

៤. ឧទាហរណ៍៖ ប្រសិនបើគ្រូនិយាយថា “ព្រះយេស៊ូវបញ្ជាឲ្យ ទះដៃ” ដូច្នេះកុមារទាំងអស់ត្រូវតែទះដៃ។

៥.បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ព្រះមានអំណាចក្នុងការប្រោសឲ្យជា និងដោះស្រាយបញ្ហាគ្រប់បែបយ៉ាងទាំងអស់។

## ៨. ខគម្ពីរចងចាំ

**លូកា ៦៖១៩** *“ទាំងអស់រកពាល់ទ្រង់ ដ្បិតមានព្រះចេស្តាចេញពីទ្រង់ មកប្រោសឲ្យ ជាទាំងអស់គ្នា”។*

## ៩. ហត្ថកម្ម «ព្រះយេស៊ូវយកចិត្តទុកដាក់ចំពោះខ្ញុំ»

សម្ភារៈដែលត្រូវការ៖ ចានក្រដាស ក្រដាសពណ៌ កាវបិត ឬស្កុត ប៊ិកពណ៌



១.ឲ្យចានក្រដាសមួយដល់កុមារម្នាក់ៗ ហើយឲ្យពួកគេសរសេរនៅកណ្តាលចានថា “ព្រះយេស៊ូវយក ចិត្តទុកដាក់ចំពោះខ្ញុំ! ដៃខ្ញុំអាចជួយអ្នកដទៃបាន»។

២. ឲ្យកុមារយកដៃពួកគេដាននៅលើក្រដាសពណ៌ ហើយកាត់វាចេញតាមរូបរាងដៃរបស់ពួកគេ។

៣. ឱ្យកុមារពិចារណាពីវិធីដែលដៃរបស់ពួកគេអាច ជួយអ្នកដទៃបាន( ឧទាហរណ៍៖ អធិស្ឋានសំរាប់អ្នកដទៃ ជួយលាងចាន ជួយសំអាតបន្ទប់ ។ល។)

៤. យកក្រដាសរូបបាតដៃដែលបានកាត់ហើយបិតនៅលើចានក្រដាស។

៥. រំឭកកុមារឲ្យចងចាំថាព្រះយេស៊ូវយកចិត្តទុកដាក់ចំពោះយើង ដូច្នេះយើងក៏គួរយកចិត្តទុកដាក់ចំពោះអ្នកឯទៀត ដូចគ្នាដែរ!

**១០. ចំរៀង** (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

សូមអាន **ម៉ាកុស ១៖២៩-៣៩**។ ព្រះយេស៊ូវមានឫទ្ធានុភាព ហើយទ្រង់អាចប្រោសយើងឲ្យជាសះស្បើយបានមិនថាពេលយើងឈឺចាប់ខាងផ្លូវកាយ ឬខាងវិញ្ញាណ។ ទោះជាព្រះយេស៊ូវជាបុត្រារបស់ព្រះក៏ដោយ ក៏ព្រះអង្គតែងតែឆ្លៀតពេលពីជីវិតដ៏មមាញឹករបស់ទ្រង់ដើម្បីអធិស្ឋានដល់ព្រះ។ នេះជាអ្វីដែលផ្ដល់កម្លាំងដល់ព្រះយេស៊ូវ។ ថ្ងៃនេះ សូមអធិស្ឋានសម្រាប់ខ្លួនអ្នកដើម្បីទទួលការព្យាបាលពីព្រះ។ ប្រហែល ជាអ្នកមានសុខភាពរាងកាយមិនស៊ូវល្អ ឬក៏អ្នកខូចចិត្ត។ ចូរទុកចិត្តថា ព្រះយេស៊ូវយកចិត្តទុកដាក់ចំពោះអ្នក ហើយចង់ឱ្យអ្នកបានជាល្អ។ សូមព្រះប្រោសអ្នកតាមរយៈការអ ធិស្ឋានរបស់អ្នកនៅពេលអ្នករៀបចំបង្រៀនកុមារតូចៗអំពីព្រះយេស៊ូវ ដែលយកចិត្តទុកដាក់ចំពោះយើងទាំងអស់គ្នា។